# សង្ខេបសាលដីកាតុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌ សាលដីកាលេខ ៨១ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ (ភាគ ៤១-៤៤)

http://www.measboralaws.com/detail/1052

**១. ពាក្យគន្លឹះ៖** មនុស្សឃាដចេតនា-ការធ្វេសប្រហែសរបស់គ្រូពេទ្យ-មរណៈភាពតាមសភាវៈនៃអ្នកជំងឺ-សាទុក្ខលើកទី១។

២. **អង្គហេតុ និង ដំណើរការនីតិវិធី៖** ជនជាប់ចោទ (គ្រូពេទ្យព្យាបាល កូនដើមបណ្ដឹងរដ្ឋប្បវេណី) ត្រូវបានចោទពីបទ មនុស្សឃាដចេតនា (ក្រៅឃុំ) ប្រព្រឹត្តនៅខេត្តកំពង់ចាម កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ បទល្មើសដែលមានចែងតាមមាត្រា ៤០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តំណាងអយ្យការអមតុលាការខេត្តកំពង់ចាម សម្រេចចេញដីកាតម្កល់រឿងឥតចាត់ការលេខ ០៥អក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០១ (រឿងនេះមិនចូលរឿងព្រហ្មទណ្ឌ)។ ដើមបណ្ដឹងរដ្ឋប្បវេណី (ម្ដាយរបស់ក្មេងទាំងពីរដែលបានស្លាប់) បានប្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចទាំងមូល។ ទាំងតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ និងសាលាឧទ្ធរណ៍ តាមសាលដីកាលេខ ៦៧ ក ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៣ បានសម្រេចតម្កល់ដីកាតម្កល់រឿងឥតចាត់ការ លេខ ០៥ ដដែល។ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងសាទុក្ខ។ ក្នុងអំឡុងពេល ពិចារណាបណ្ដឹងសាទុក្ខ តំណាងមហាអយ្យការអមតុលាការកំពូល បានសន្និដ្ឋានថា សាលដីកាសម្រេចសេចក្ដីនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ។ តុលាការកំពូល បានសម្រេច ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៦៧ ក ទាំងមូល និងបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣ របស់តុលាការកំពូលទៅអយ្យការអមតុលាការខេត្តកំពង់ចាម ដើម្បីចាត់ការបន្ត។

៣. ខ្លឹមសារនៃសំអាងហេតុរបស់តុលាការកំពូល៖- *១. យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូច អយ្យការអមតុលាការខេត្តកំពង់ចាមដែរ ដែលតម្កល់រឿងមរណៈភាពនៃកុមារទាំងពីរនាក់នេះ ពុំចាត់ការ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះថាពុំមានភ័ស្តុតាងណាមួយបញ្ជាក់ថា មរណៈភាពនៃកុមារទាំងពីរ ជាមរណៈភាពតាមសភាវៈនៃអ្នកជំងឺ ឬបណ្ដាលមកពីការធ្វេសប្រហែសជាបទអាដ្ឋារបស់អ្នកព្យាបាល ឬ អាណាព្យាបាលឡើយ។*(ទំ.៤)

**<u>កំណត់សំគាល់</u>៖** ការស្លាប់របស់មនុស្ស អាចបណ្តាលមកពីការធ្វេសប្រហែស (negligence)។ ក្នុងការព្យាបាល គេប្រើពាក្យ "ការធ្វេសប្រហែសរបស់គ្រូពេទ្យ" (Medical Negligence/Medical Malpractice)។ វាជាការព្យាបាល មិនតាមវិធីព្យាបាលត្រឹមត្រូវ ជាដើម ដែលអាចធ្វើឲ្យជនរងគ្រោះជាអ្នកជំងឺ ឬអ្នកមានរបួស (គ្រោះថ្នាក់ចរាចរ) ស្លាប់។ ក្នុងករណីខ្លះ អ្នកជំងឺ ឬអ្នករបួសមានសភាពធ្ងន់ធ្ងរពេក ទោះបីគ្រូពេទ្យមិនធ្វេសប្រហែស ក៏មិនអាចជួយសង្គ្រោះបានដែរ។ ករណីនេះ ការចូលរួមរបស់គ្រូពេទ្យ មិនផ្តាច់ចំណងហេតុ និងផល (breach of causation chain)។ អ្នករបួស ឬជំងឺស្លាប់តាមធម្មជាតិនៃស្ថានភាពជំងឺ (natural causing of dying)។ តុលាការកំពូលកម្ពុជា ក្នុងសាលដីកានេះ ប្រើពាក្យ *"មរណៈភាពនៃកុមារទាំងពីរ ជាមរណៈភាពតាមសភាវៈនៃអ្នកជំងឺ"* ទំនងជាក្នុងន័យនេះហើយ។ វាគឺជា វិធានសម្រាប់ វាស់វែងដាក់ការទទួលខុសត្រូវ។

សូមចុចលើតំណភ្ជាប់និងអានទ្រឹស្តីពាក់ព័ន្ធជាបន្ថែមដើម្បីកាន់តែយល់៖

1.*mens rea*, http://www.measboralaws.com/detail/1060;
2.omission, http://www.measboralaws.com/detail/1050,
3. causation, http://www.measboralaws.com/detail/1053